**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក**

លេខ៖.........០៣២/២៤.............គ.ស.ច.គ.

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងសមាសភាពក្រុមការងារត្រួតពិនិត្យយានយន្តកែច្នៃខុសលក្ខណៈ បច្ចេកទេស ចំណុះគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

## គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៧/០០២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨៤អនក្រ.បក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- បានឃើញសេចក្តីសម្រេចលេខ ១៩១សសរ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាល ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- យោងតាមការចាំបាច់របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក

## **សម្រេច**

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាព ក្រុមការងារត្រួតពិនិត្យយានយន្តកែច្នៃខុសលក្ខណៈបច្ចេកទេស ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **សេង ឈួន** រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធាន

២-ឯកឧត្តមបណ្ឌិត **គឹម សន្តិភាព** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ អនុប្រធាន

៣-ឯកឧត្តម **ហ៊ីម យ៉ាន** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អនុប្រធាន

៤-ឯកឧត្តម **មុី ម៉ារ៉ាឌី** អនុរដ្ឋលេខាធិការ ក្រសួងសាធារណការនិងដឹកជញ្ជូន អនុប្រធានអចិន្ត្រៃយ៍

៥-ឯកឧត្តម **ឈួន វ៉ន់** អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក អនុប្រធាន

៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ចេង ហាក់** អគ្គស្នងការរងនគរបាលជាតិ អនុប្រធាន

៧-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហេង ចាន់ធារី** ប្រធាននាយកដ្ឋាននគបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ ក្រសួងមហាផ្ទៃ សមាជិក

៨-លោក **ព្រុំ វណ្ណា** ប្រធាននាយកដ្ឋានសុវត្ថិភាពចរាចរណ៍ផ្លូវគោក សមាជិកអចិន្ត្រៃយ៍

៩-លោក **ណុម សុធនវិសុទ្ធ** ប្រធាននាយកដ្ឋានស្រាវជ្រាវផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ សមាជិក

១០-លោក **ផល្លា សុជាតាមុនី** អនុប្រធាននាយកដ្ឋានកិច្ចការអនុគ្រោះទោស សមាជិក

១១-លោកឧត្តមសេនីយ៍ទោ **សុខ ណុម** អនុប្រធាននាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ ក្រសួងមហាផ្ទៃ សមាជិក

១២-លោកឧត្តមសេនីយ៍ត្រី **យ៉ើ យ៉ាន់ណា** អនុប្រធាននាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ ក្រសួងមហាផ្ទៃ សមាជិក

១៣-លោក **សាំង ពៅ** អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក សមាជិក

១៤-លោក **អ៊ុន វ៉ាត** ប្រធានការិយាល័យត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត សមាជិក

១៥-លោកវរសេនីយ៍ទោ **ប៊ិន ឥស្សរ** នាយការិយាល័យសណ្តាប់ធ្នាប់ និងអន្តរាគមន៍ស្នងការដ្ឋានផែនការ ប្រតិបត្តិ និងហ្វឹកហ្វឺន កងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១៦-លោក **ពេជ្រ ច័ន្ទបណ្ឌិត** ប្រធានការិយាល័យស្រាវជ្រាវ និងស្ថិតិ សមាជិក

**ប្រការ២.-**

ក្រុមការងារត្រួតពិនិត្យយានយន្តកែច្នៃខុសលក្ខណៈបច្ចេកទេសមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- កសាងផែនការ និងកម្មវិធីប្រតិបត្តិការត្រួតពិនិត្យយានយន្តកែច្នៃខុសលក្ខណៈបច្ចេកទេស
- ផ្សព្វផ្សាយជាសាធារណៈតាមគ្រប់រូបភាពដល់ម្ចាស់យានយន្តឱ្យភ្ញាក់រលឹក ធ្វើការកែតម្រូវលក្ខណៈបច្ចេកទេសយានយន្តរបស់ខ្លួនស្របតាមការកំណត់ ដែលមានចែងក្នុងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងបទដ្ឋាននានា និងផ្សព្វផ្សាយវិធានការរឹតបន្តឹងការអនុវត្តច្បាប់របស់សមត្ថកិច្ចចំពោះករណីល្មើស

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចប្រតិបត្តិការត្រួតពិនិត្យយានយន្តកែច្នៃខុសលក្ខណៈបច្ចេកទេស របស់ក្រុមការងារថ្នាក់រាជធានី ខេត្ត
- ធ្វើកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីស្វែងរកជំនួយគាំទ្រដល់កិច្ចប្រតិបត្តិការ
- ធ្វើរបាយការណ៍ការងារជូន គ.ស.ច.គ. តាមកាលកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀតដែល គ.ស.ច.គ. ប្រគល់ឱ្យ។

**ប្រការ៣.-**

សមាជិកទាំងអស់នៃក្រុមការងារ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានក្រុមការងារ។ សមាជិកក្រុមការងារអាចចាត់បញ្ជូនមន្ត្រីក្រោមឱវាទឱ្យជួយការងារតាមការចាំបាច់ បន្ទាប់ពីមានការអនុញ្ញាតពីប្រធានក្រុមការងារ។

**ប្រការ៤.-**

សេចក្តីសម្រេចលេខ០៥៥/១៩ គ.ស.ច.គ. ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារចំនួន៨ក្រុម ចំណុះគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកត្រូវមានអនុភាពអនុវត្តតទៅមុខទៀត រហូតដល់មានសេចក្តីសម្រេចថ្មីមកជំនួស លើកលែងតែក្រុមការងារត្រួតពិនិត្យយានយន្តកែច្នៃខុសលក្ខណៈបច្ចេកទេស។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៦.-**

ប្រធានអនុគណៈកម្មការទី១ ប្រធានអនុគណៈកម្មការទី២ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ស.ច.គ. ប្រធានអនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី ខេត្ត និងសាមីខ្លួនក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែសីហា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជា**
**ប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អនុគណៈកម្មការសុវត្ថិភាពចរាចរណ៍ផ្លូវគោករាជធានី ខេត្ត
-ដូចប្រការ៦
-ឯកសារ កាលប្បវត្តិ